# នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jan-2015, 15:21
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិននឹងសវនាការលើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

យ៉េត ចរិយា

William SMITH

ផែន ពៅ

ទី ស្រ៊ុនណា

Emmanuel ALTIT
Olivier BAHOUGNE
Patrick BAUDOIN
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Michael Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI
Beini YE

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

## I. សេចក្តីផ្តើម

១. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមប្រកាសពីចេតនារបស់ខ្លួន តាមរយៈញត្តិនេះ ដើម្បីរក្សាសិទ្ធិក្នុងការសួរដេញដោលលោកវេជ្ជបណ្ឌិត CHAN Kin Ming និងលោកវេជ្ជបណ្ឌិត ហួត លីនណា ក្នុងអំឡុងពេលសវនាការលើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ (“សវនាការ”) ដែលគ្រោងធ្វើឡើងនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទទួលបានសិទ្ធិសួរដេញដោលអ្នកជំនាញ ក្នុងពេលសវនាការលើសម្បទារនាពេលកន្លងមក[1] ហើយការដកហូតសិទ្ធិនេះនៅពេលសវនាការខាងមុខ គឺជាការធ្វើឲ្យខូចខាតជាមូលដ្ឋាននូវលទ្ធភាពរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការតំណាងផលប្រយោជន៍របស់ក្រុមរួមដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី ០០២/០២។

## II. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាចាត់តាំងអ្នកជំនាញ ឲ្យធ្វើការវាយតម្លៃសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ (“ដីកា”)[2]។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យលោកវេជ្ជបណ្ឌិត CHAN Kin Ming និងនិងលោកវេជ្ជបណ្ឌិត ហួត លីនណា (“អ្នកជំនាញ”) ធ្វើការវាយតម្លៃ នួន ជា និង ខៀវ សំផន (“សហជនជាប់ចោទ”) ហើយ

[1] ប្រតិចារឹកសវនាការសម្រាប់សំណុំរឿង ០០២, ឯកសារ E1/9.1, ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១, ERN 00738784-00738794, ប្រតិចារឹកសវនាការសម្រាប់សំណុំរឿង ០០២, ឯកសារ E1/10.1, ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១, ERN 00729295-00739398, ប្រតិចារឹកសវនាការសម្រាប់សំណុំរឿង ០០២, ឯកសារ E1/12.1, ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១, ERN 00749134-00749146, ប្រតិចារឹកសវនាការសម្រាប់សំណុំរឿង ០០២, ឯកសារ E1/118.1, ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២, ERN 00844881-00844884, ប្រតិចារឹកសវនាការសម្រាប់សំណុំរឿង ០០២, ឯកសារ E1/119.1, ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២, ERN 00845044-00845064, ប្រតិចារឹកសវនាការសម្រាប់សំណុំរឿង ០០២, ឯកសារ E1/143.1, ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២, ERN 00861449-00861452។

[2] ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ, ឯកសារ E329, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤។

បន្ទាប់មកត្រូវផ្តល់ព័ត៌មានទៅអង្គជំនុំជម្រះសាលាដំបូង តាមរយៈទម្រង់នៃរបាយការណ៍របស់អ្នកជំនាញ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលកំណត់ក្នុងរឿងក្តី *Strugar*[3]។

៣. ដីកាបានកំណត់កាលបរិច្ឆេទសវនាការសម្រាប់ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ដើម្បីអនុញ្ញាតឱ្យអ្នកជំនាញបង្ហាញលទ្ធផលរបស់ពួកគាត់ និងឆ្លើយទៅនឹងសំណួរនានារបស់មេធាវីការពារក្តី និងសហព្រះរាជអាជ្ញា[4]។ ដីកាមិនបានបញ្ជាក់ថាតើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យសួរដេញដោលអ្នកជំនាញ អំពីលទ្ធផលរបស់ពួកគាត់ដែរឬយ៉ាងណានោះទេ។

## III. សារណា

**ក. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរក្សាសិទ្ធិសួរដេញដោលអ្នកជំនាញ លើការសន្និដ្ឋានដែលបានធ្វើឡើងនៅក្នុងរបាយការណ៍អ្នកជំនាញ ទាក់ទងសម្បទារបស់សហជនជាប់ចោទក្នុងការចូលរួមសវនាការ។**

៤. ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ គឺជាជនរងគ្រោះទាំងឡាយដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ ត្រូវបានចាត់ទុកថាអាចទទួលយកបានដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ហើយដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីនៃកិច្ចដំណើរការនីតិវិធី ដូចគ្នាទៅនឹងជនជាប់ចោទ និងសហព្រះរាជអាជ្ញាដែរ[5]។

៥. វិធានផ្ទៃក្នុងនៃ អ.វ.ត.ក ("វិធានផ្ទៃក្នុង") បានទទួលស្គាល់យ៉ាងច្បាស់លាស់នូវតម្រូវការ ក្នុងការការពារផលប្រយោជន៍របស់ជនជាប់ចោទ និងជនរងគ្រោះ[6] ដែលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ហើយដើម្បីជំរុញគោលដៅនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានភារកិច្ចក្នុងការតំណាងប្រកបដោយប្រសិទ្ធិភាពនូវផលប្រយោជន៍តែមួយគត់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលរួមគ្នាជាក្រុមតែមួយ[7]។

---

[3] ដីកាចាត់តាំងអ្នកជំនាញ, កថាខណ្ឌ ៦ដល់៨។

[4] ដីកាចាត់តាំងអ្នកជំនាញ

[5] វិធានផ្ទៃក្នុង ទំព័រ ៨១ "ភាគី"។

[6] ដូចជើងទំព័រខាងលើ វិធាន២១(១)។

[7] ដូចជើងទំព័រខាងលើ វិធាន១២ស្ទួនបី។

៦. អង្គជំនុំជម្រះសាលាដំបូងនាពេលកន្លងមក បានទទួលស្គាល់រួចហើយនូវតម្រូវការ ក្នុងការធានាថា នីតិវិធីក្នុងការសួរដេញដោលប្រព្រឹត្តទៅដោយយុត្តិធម៌ និងចំពោះមុខ ដែលធានាបាននូវតុល្យភាព នៃសិទ្ធិរបស់ភាគី[8] ក្នុងអំឡុងពេលសវនាការប្រហាក់ប្រហែលគ្នា លើសម្បទាក្នុងការចូលរួមសវនាការ ដោយបានអនុញ្ញាតឲ្យសហមេធាវីនាំមុខ ព្រមទាំងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ធ្វើការសួរដេញដោលទៅលើអ្នកជំនាញ អំពីសេចក្តីសន្និដ្ឋានដែលបានធ្វើឡើងនៅក្នុងរបាយការណ៍របស់អ្នកជំនាញ[9]។

៧. ដើម្បីធានាថា ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងនាមជាភាគីមួយនៃកិច្ចដំណើរការនីតិវិធី មិនត្រូវបានប៉ះពាល់ ហើយផលប្រយោជន៍របស់ពួកគាត់ នៅតែត្រូវបានតំណាងប្រកបដោយប្រសិទ្ធិភាពនោះ ជាការចាំបាច់ត្រូវបន្តរក្សាឲ្យមាននូវនីតិវិធីសួរដេញដោលចំពោះមុខក្នុងសវនាការ ដោយរួមបញ្ចូលទាំងសហមេធាវីនាំមុខផងដែរ។

## IV. សំណើ

ហេតុដូច្នេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើដោយក្តីគោរពចំពោះអង្គជំនុំជម្រះសាលាដំបូង៖

(១) បញ្ជាក់ឡើងវិញពីសិទ្ធិរបស់សហមេធាវីនាំមុខ ក្នុងការសួរដេញដោលអ្នកជំនាញ ក្នុងអំឡុងពេលសវនាការលើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការដែលបានកំណត់ទុក។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

---

[8] ដូចជើងទំព័រខាងលើ វិធាន២១(១)(ក)។

[9] ដីកាកំណត់កាលបរិច្ឆេទសវនាការស្តីពី បញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ, ឯកសារ E110, ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១, ERN 00725388, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ការកំណត់កាលបរិច្ឆេទសម្រាប់ការវាយតម្លៃឡើងវិញ និងសវនាការលើសម្បទាក្នុងការចូលរួមសវនាការរបស់ អៀង ធីរិទ្ធ", ឯកសារ E318/1/7/13, ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១២, ERN 00818576។ សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ និងដីកាចាត់តាំងអ្នកជំនាញ, ឯកសារ E301/10, ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤, កថាខណ្ឌ ១៦, ERN 00975156។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ | ពេជ អង្គ<br>សហមេធាវីជាតិនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីអន្តរជាតិនាំមុខ | | |